TOWER HEALTH
Advancing Health. Transforming Lives.

# សិទ្ធិ និងការការពាររបស់អ្នកពីវិក្កយបត្រគិតប្រាក់ផ្នែកវេជ្ជសាស្ត្រដែលមិនបានរំពឹងទុក

ការចេញវិក្កយបត្រគិតប្រាក់ផ្នែកវេជ្ជសាស្ត្រអាចជារឿងពិបាកនឹងយល់។ យើងចង់ឱ្យអ្នកយល់អំពីសិទ្ធិរបស់អ្នក។

**សិទ្ធិរបស់អ្នក៖**

- គ្មានការចេញវិក្កយបត្រដែលមិនបានរំពឹងទុក
- គ្មានការចេញវិក្កយបត្រសមតុល្យ
- ការប៉ាន់ស្មានតម្លៃដោយសុទ្ធចិត្ត ប្រសិនបើអ្នកមិនមានធានារ៉ាប់រងសុខភាពទេនោះ

**ការពន្យល់ពីថ្លៃសេវាពី "ក្នុងបណ្តាញ" និង "ក្រៅបណ្តាញ"**

ដើម្បីរក្សាតម្លៃឱ្យនៅទាប គម្រោងសុខភាពរបស់អ្នកធ្វើកិច្ចសន្យាជាមួយនឹងអ្នកផ្តល់សេវា និងមណ្ឌលសុខភាពនានា។ ប្រសិនបើអ្នកប្រើសេវាកម្មទាំងនោះ ថ្លៃសេវារបស់អ្នកមានតិចជាង។ គេហៅវាថា **ក្នុងបណ្តាញ**។

ការទៅរកអ្នកផ្តល់សេវា ឬមណ្ឌលសុខភាព ដែលគម្រោងរបស់អ្នកមិនមានកិច្ចសន្យាជាមួយ ដែលគេហៅថា **ក្រៅបណ្តាញ**។ ប្រសិនបើអ្នកជ្រើសរើសប្រើប្រាស់ការថែទាំនៅក្រៅបណ្តាញ ថ្លៃសេវារបស់អ្នកនឹងមានខ្ពស់ជាង។

**គ្មានការចេញវិក្កយបត្រដែលមិនបានរំពឹងទុក**

ការចេញវិក្កយបត្រដែលមិនបានរំពឹងទុកគឺជាវិក្កយបត្រដែលនឹកស្មានមិនដល់ ពេលដែលអ្នកទទួលបានការព្យាបាល និងត្រូវបានគេគិតថ្លៃពីសេវាក្រៅបណ្តាញ ប៉ុន្តែអ្នកមិនបានជ្រើសរើសការថែទាំនៅក្រៅបណ្តាញដោយចេតនានោះទេ។ រឿងនេះអាចកើតឡើងប្រសិនបើអ្នកត្រូវការការថែទាំបន្ទាន់ និងស្ថិតនៅក្រៅតំបន់របស់អ្នក។ វាក៏អាចកើតឡើងប្រសិនបើអ្នកមិនដឹងថា អ្នកផ្តល់សេវាស្ថិតនៅក្រៅបណ្តាញ ព្រោះថាអ្នកទទួលបានការព្យាបាលនៅក្នុងមណ្ឌលថែទាំក្នុងបណ្តាញ។

**គ្មានការចេញវិក្កយបត្រសមតុល្យ**

ការចេញវិក្កយបត្រសមតុល្យគឺជាពេល ដែលអ្នកត្រូវបានគេយកថ្លៃសេវាសម្រាប់ចំនួនខុសគ្នារវាងតម្លៃក្នុងបណ្តាញ និងតម្លៃក្រៅបណ្តាញសម្រាប់ការថែទាំបន្ទាន់ ឬសម្រាប់អ្នកផ្តល់សេវានៅក្រៅបណ្តាញ ដែលអ្នកមិនបានយល់ព្រមមុនពេលទទួលបានការថែទាំនោះ។ ការគិតថ្លៃនេះជាធម្មតាមានចំនួនច្រើនជាងតម្លៃក្នុងបណ្តាញ។ វាមិនអាចរាប់បញ្ចូលក្នុងប្រាក់កាត់កងនោះទេ។

**អ្នកត្រូវបានការពារពីការចេញវិក្កយបត្រសមតុល្យសម្រាប់៖**

**សេវាសង្គ្រោះបន្ទាន់**

ប្រសិនបើអ្នកមានលក្ខខណ្ឌសុខភាពដែលជាការសង្គ្រោះបន្ទាន់ ឬទទួលសេវាកម្មសង្គ្រោះបន្ទាន់ពីអ្នកផ្តល់សេវា ឬមណ្ឌលថែទាំក្រៅបណ្តាញមួយ តម្លៃដែលអ្នកផ្តល់សេវា ឬមណ្ឌលថែទាំភាគច្រើនអាចចេញវិក្កយបត្រទៅឱ្យអ្នកគឺថ្លៃចំណាយរួមក្នុងបណ្តាញគម្រោងរបស់អ្នក (ដូចជាការបង់ចំណាយរួម និងការធានារ៉ាប់រងរួម)។ អ្នកមិនអាចទទួលបានវិក្កយបត្រសមតុល្យសម្រាប់សេវាសង្គ្រោះបន្ទាន់ទាំងនេះទេ។ នេះរួមបញ្ចូលទាំងសេវាកម្ម ដែលអ្នកអាចទទួលបានបន្ទាប់ពីអ្នកស្ថិតក្នុងស្ថានភាពសុខភាព ដែលមានស្ថិរភាព លុះត្រាតែអ្នកផ្តល់ការយល់ព្រមជាលាយលក្ខណ៍អក្សរ ហើយបោះបង់ចោលការការពាររបស់អ្នកចំពោះការមិនត្រូវបានគេចេញវិក្កយបត្រសមតុល្យសម្រាប់សេវាក្រោយពេលមានស្ថិរភាពសុខភាពទាំងនេះ។

**សេវាកម្មជាក់លាក់ក្នុងមន្ទីរពេទ្យ ឬមជ្ឈមណ្ឌលសង្គ្រោះបន្ទាន់ក្នុងបណ្តាញ**

ពេលអ្នកទទួលបានសេវាកម្មពីមន្ទីរពេទ្យ ឬមជ្ឈមណ្ឌលសង្គ្រោះបន្ទាន់នៅក្នុងបណ្តាញ អ្នកផ្តល់សេវាជាក់លាក់មួយចំនួននៅទីនោះអាចនៅក្រៅបណ្តាញ។ ក្នុងករណីទាំងនេះ តម្លៃច្រើនបំផុត ដែលអ្នកផ្តល់សេវាទាំងនេះភាគច្រើនអាចនឹងចេញវិក្កយបត្រគិតប្រាក់ទៅឱ្យអ្នកគឺសម្រាប់ចំនួននៃការរួមចំណែកក្នុងថ្លៃចំណាយនៅក្នុងបណ្តាញនៃគម្រោងរបស់អ្នក។ ចំណុចនេះអនុវត្តចំពោះថ្នាំសង្គ្រោះបន្ទាន់ ថ្នាំសន្លប់ ការព្យាបាលរោគ ការព្យាបាលដោយវិទ្យុសកម្ម មន្ទីរពិសោធន៍ ទារកទើបនឹងកើត ជំនួយការគ្រូពេទ្យវះកាត់ គ្រូពេទ្យនៅក្នុងមន្ទីរពេទ្យ ឬសេវារបស់ពេទ្យសង្គ្រោះបន្ទាន់។ អ្នកផ្តល់សេវាទាំងនេះមិនអាចចេញវិក្កយបត្រសមតុល្យមកឱ្យអ្នក និងមិនអាចសុំឱ្យអ្នកបោះបង់ការការពាររបស់អ្នក ដើម្បីកុំឱ្យមានការចេញវិក្កយបត្រសមតុល្យនោះទេ។

**ប្រសិនបើអ្នកទទួលបានសេវាផ្សេងទៀតនៅក្នុងមណ្ឌលសុខភាពក្នុងបណ្តាញទាំងនេះ អ្នកផ្តល់សេវាក្រៅបណ្តាញ មិនអាច ចេញវិក្កយបត្រសមតុល្យឱ្យអ្នកទេ លុះត្រាតែអ្នកផ្តល់ឱ្យការយល់ព្រមជាលាយលក្ខណ៍អក្សរ និងបោះបង់ចោលការការពាររបស់អ្នក។**

**ការប៉ាន់ស្មានតម្លៃដោយសុទ្ធចិត្ត**

ការប៉ាន់ស្មានតម្លៃដោយសុទ្ធចិត្តគឺជាការចេញតម្លៃ ផ្អែកលើអ្វីដែលអ្នកដឹងនៅពេលដែលតម្លៃប៉ាន់ស្មាននោះត្រូវបានធ្វើឡើង។ វារួមបញ្ចូលទាំងតម្លៃប៉ាន់ស្មាននៃការថែទាំដែលគេមានបំណងចង់គិតសម្រាប់ការជួបពិនិត្យរបស់អ្នក រួមបញ្ចូលទាំងការថែទាំដែលពាក់ព័ន្ធ ដែលត្រូវបានរំពឹងទុកយ៉ាងសមហេតុផលថានឹងទទួលបានជាលទ្ធផលផ្ទាល់នៃការជួបពិនិត្យ។ អ្នកមានសិទ្ធិទទួលបានការប៉ាន់ស្មានតម្លៃដោយសុទ្ធចិត្ត ប្រសិនបើអ្នកមិនមានធានារ៉ាប់រងទេនោះ ឬប្រសិនបើអ្នកជ្រើសរើសបង់ប្រាក់ដោយខ្លួនឯងសម្រាប់ការថែទាំផ្នែកវេជ្ជសាស្ត្ររបស់អ្នក។ ដោយសារតែការព្យាបាលរបស់អ្នកអាចមានផ្សេងៗពីគ្នា ហើយលក្ខខណ្ឌសុខភាពរបស់អ្នកអាចផ្លាស់ប្តូរ យើងមិនអាចធានាថាការប៉ាន់ស្មានតម្លៃដោយសុទ្ធចិត្តនេះនឹងត្រូវគ្នានឹងតម្លៃនៃការថែទាំសុខភាពចុងក្រោយនោះទេ។

**ការការពាររបស់អ្នក៖**

អ្នកមានទំនួលខុសត្រូវក្នុងការបង់ប្រាក់សម្រាប់ **ចំណែករបស់អ្នក** ពីតម្លៃនៃការថែទាំវេជ្ជសាស្ត្ររបស់អ្នក (ការបង់ប្រាក់រួម សហធានារ៉ាប់រង និងប្រាក់កាត់កង)។

អ្នកនឹងមិនត្រូវបានតម្រូវឱ្យលះបង់ការការពាររបស់អ្នកពីការចេញវិក្កយបត្រសមតុល្យនោះឡើយ។ អ្នកមិនត្រូវបានតម្រូវឱ្យប្រើការថែទាំនៅក្រៅបណ្តាញនោះទេ។

ជាទូទៅ ផែនការសុខភាពរបស់អ្នកត្រូវតែ៖

- ធានារ៉ាប់រងចំពោះសេវាសង្គ្រោះបន្ទាន់ដោយមិនបាច់មានការអនុញ្ញាតទុកជាមុន
- ធានារ៉ាប់រងចំពោះសេវាសង្គ្រោះបន្ទាន់ពីអ្នកផ្តល់សេវានៅក្រៅបណ្តាញ និងទទួលវិក្កយបត្រគិតប្រាក់សម្រាប់សេវាក្នុងបណ្តាញ លុះត្រាតែអ្នកផ្តល់ឱ្យការព្រមព្រៀងជាលាយលក្ខណ៍អក្សរ។
- រាប់ចំនួនប្រាក់ដែលអ្នកបង់ចំណាយសម្រាប់ការថែទាំសង្គ្រោះបន្ទាន់ ឬសេវាកម្មនៅក្រៅបណ្តាញចូលទៅក្នុងដែនកំណត់នៃប្រាក់ចេញពីហោប៉ៅ និងប្រាក់កាត់កង។

**កន្លែងដែលទទួលបានជំនួយ**

ប្រសិនបើអ្នកមានសំណួរ ឬកង្វល់ណាមួយអំពីការជួបពិនិត្យរបស់អ្នក រួមបញ្ចូលទាំងសំណួរអំពីអ្នកផ្តល់សេវានៅក្នុងបណ្តាញ ការប៉ាន់ស្មានតម្លៃដោយសុទ្ធចិត្ត ក្តីកង្វល់នានាអំពីវិក្កយបត្រគិតប្រាក់របស់អ្នកណាមួយ សូមទំនាក់ទំនងមកកាន់សេវាបម្រើអតិថិជនរបស់ Tower Health តាមលេខ 484-−628-−3528 ។ បុគ្គលិករបស់យើងទទួលបានការបណ្តុះបណ្តាល និងត្រៀមខ្លួនរួចរាល់ដើម្បីជួយអ្នក។

**ជំនួយបន្ថែមក្នុងការស្វែងរកអ្នកផ្តល់សេវាក្នុងបណ្តាញ**

អ្នកអាចទាក់ទងក្រសួងធានារ៉ាប់រងនៃរដ្ឋ Pennsylvania (Pennsylvania Insurance Department) តាមគេហទំព័រ www.insurance.pa.gov/nosurprise ឬតាមទូរសព្ទលេខ 1-877-881-6388 ឬ TTY/TTD: 717-783-3898 ប្រសិនបើអ្នកមានការលំបាកក្នុងការស្វែងរកអ្នកផ្តល់សេវា ឬមណ្ឌលសុខភាពនៅក្នុងបណ្តាញគម្រោងរបស់អ្នក។

**ជំនួយបន្ថែម ប្រសិនបើអ្នកជឿថាគេចេញវិក្កយបត្រខុសមកឱ្យអ្នក**

អ្នកក៏អាចទាក់ទងទៅកាន់មជ្ឈមណ្ឌលសម្រាប់សេវា Medicare នៅសហរដ្ឋអាមេរិក (CMS) តាមលេខ 1−800−MEDICARE (1−800−633−4227) ឬមើលនៅគេហទំព័រ https://www.cms.gov/nosurprises (https://www.cms.gov/nosurprises) សម្រាប់ព័ត៌មានបន្ថែមអំពីសិទ្ធិរបស់អ្នកនៅក្រោមច្បាប់សហព័ន្ធ។

**ជំនួយបន្ថែមជាមួយនឹងការប៉ាន់ស្មានតម្លៃដោយសុទ្ធចិត្ត**

អ្នកក៏អាចទទួលបានព័ត៌មានបន្ថែមអំពីសិទ្ធិរបស់អ្នកចំពោះការប៉ាន់ស្មានតម្លៃដោយសុទ្ធចិត្តនៅគេហទំព័រ cms.gov/nosurprises (https://www.cms.gov/nosurprises) ឬទូរសព្ទទៅកាន់លេខ 1−800−MEDICARE (1−800−633−4227)។